# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ១ - ព្រះរាជក្រម

**ព្រះរាជក្រមលេខ ជស.កម.១០៩៥.០១**

**ច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសំរាប់ឆ្នាំ ១៩៩៤**

**យើង ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេស រដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ប្រកាសអោយប្រើ**

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការទូទាត់ ថវិការដ្ឋសំរាប់ ឆ្នាំ ១៩៩៤ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់ស្តីពីការទូទាត់ថវិកាជាតិសំរាប់ឆ្នាំ ១៩៩៤

## ភាគទី ១
## បទបញ្ញត្តិ នៃច្បាប់ស្តីពីការទូទាត់ថវិកាជាតិ

### ជំពូកទី ១ :
### បទបញ្ញត្តិទូទៅ

**មាត្រា ១ :** ត្រូវបានយល់ព្រមតាមការអនុវត្តន៍ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម លេខ ០៨ ន.ស៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផល ÷

- សរុបចំណាយចំនួន ........................ ១.០២០.១៣២ លានរៀល
- សរុបចំណូលចំនួន ........................ ១.០០២.០១៧ លានរៀល

ដូចមានចែងក្នុងតារាងខាងក្រោមនេះ ÷ ឯកតា : លានរៀល

១–សរុបចំណូលចំណាយ នៃកិច្ចប្រតិបត្តិការត្រូវបានបញ្ជាក់ដោយមានលក្ខណៈចង្អុលបង្ហាញ ពីព្រោះកិច្ចប្រតិបត្តិការដែលអនុវត្តបានដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់ធនាគារជាតិ ហើយមិនបានចុះកិច្ចបញ្ជីការក្នុងគណនេយ្យធនាគារទេ ។ កិច្ចប្រតិបត្តិការ នេះគ្រាន់តែជាកម្មវត្ថុ នៃការប៉ាន់ប្រមាណតួលេខមួយ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នា ជាមួយអ្នកផ្តល់មូលនិធិ ។ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នាជាមួយអ្នកផ្តល់មូលនិធិ ។ ចំណែកឯចំណាយមួយភាគរបស់ក្រសួងការពារជាតិក៏មិនបានចុះកិច្ចបញ្ជីការនៅក្នុងគណនេយ្យ ធនាគារជាតិដែរ ហើយការចំណាយនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយការខ្ចី ប្រាក់ពីផ្នែកឯកជន ខាងក្រៅនិង ក្នុងប្រទេសព្រមទាំងដោយប្រភពធនធានជាតិដែលបានកំណត់ ។

# ជំពូកទី ២
# បទបញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការថវិកា

**មាត្រា ២** : ការប្រមូលចំណូលជាគុណប្រយោជន៍ នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករផលិតផល និង ផលទុន ព្រមទាំងការធ្វើអោយសំរេចនូវ អំណោយមូលនិធិឧបតិភាគ និង ធនធានបានមកពី ការខ្ចីបុលដែលបានអនុញ្ញាតអោយគ្រោងទុកនៅក្នុងច្បាប់ ស្តីពីការតម្រូវ នៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ មានទឹកប្រាក់សរុប ៦៣៧.៥០០ លានរៀល

ការអនុវត្តន៍បានមានចំនួនទឹកប្រាក់ ៦៧៧.១៦២ លានរៀល
ដូច្នេះមានចំណូលលើសចំនួន ៣៩.៦៦២ លានរៀល
ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷

| | | | |
|---|---|---|---|
| – ចំណូលផ្ទៃក្នុងជាប្រចាំ | : គំរោងកែតម្រូវ | ៤៩៦.៧០០ | លានរៀល |
| | : សំរេចបាន | ៥៦៥.២៧០ | លានរៀល |
| | : មានចំនួនលើស | ៦៨.៥៧០ | លានរៀល |
| – ចំណូលផ្ទៃក្នុងជាមូលធន | : គំរោងកែតម្រូវ | ២៣.៨០០ | លានរៀល |
| | : សំរេចបាន | ១.២៣៧ | លានរៀល |
| | : មានចំនួនខ្វះ | ២២.៥៦៣ | លានរៀល |
| – ចំណូលខាងក្រៅជាមូលធន | : គំរោងកែតម្រូវ | ១១៧.០០០ | លានរៀល |
| | : សំរេចបាន | ១១០.៦៥៥ | លានរៀល |
| | : មានចំនួនខ្វះ | ៦.៣៤៥ | លានរៀល |

**មាត្រា ៣** : ចំណាយថវិកាទូទៅរបស់រដ្ឋដែលត្រូវទទួលការអនុវត្តន៍តាមការគ្រោងទុកនៅក្នុងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

| | | |
|---|---|---|
| មានចំនួនទឹកប្រាក់សរុប | ៦៣៧.៥០០ | លារៀល |
| ការអនុវត្តន៍បានមានចំនួនទឹកប្រាក់ | ៦៨០.៥៣៧ | លានរៀល |
| ដូច្នេះមានចំនួនលើស | ២១.៥៤៧ | លានរៀល |

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ៖

| | | |
|---|---|---|
| - ចំណាយជាប្រចាំ | : គំរោងកែតម្រូវ | ៥៨៥.៦០០ លានរៀល |
| | : សំរេចបាន | ៥៨៩.៥៨៨ លានរៀល |
| | : មានចំនួនលើស | ៤.១៣៨ លានរៀល |
| - ចំណាយជាមូលធន | : គំរោងកែតម្រូវ | ៥១.៩០០ លានរៀល |
| | : សំរេចបាន | ៦៩.៣០៩ លានរៀល |
| | : មានចំនួនលើស | ១៧.៤០៩ លានរៀល |

**មាត្រា ៤** : ការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូលចំណាយតាមច្បាប់ ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ ដែលសំរេចបានដោយ រតនាគារជាតិ បានបញ្ជាក់នៅក្នុងមាត្រា ២ និង ៣ ខាងលើ បានបង្ហាញជាលទ្ធផលនូវចំណូលលើសចំណាយដូចតទៅ :

- ចំណូលថវិកាដែលសំរេចបានដោយរតនាគារ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤........................ ៦៧៧.១៦២ លានរៀល
- ចំណាយថវិកាដែលសំរេចបានដោយរតនាគារ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤........................ ៦៥៩.០៤៧ លានរៀល
- ចំនួនលើសនៃគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ : ១៨.១១៥ លានរៀល

ដោយអនុលោមទៅតាមបទបញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែល ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ឆ្នាំ ១៩៩៣ ចំនួន លើសនៃគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ មានចំនួនទឹកប្រាក់ ១៨.១១៥ លានរៀល ត្រូវបានកត់ត្រានៅ « គណនីលទ្ធផលរតនាគារ ដែលបានបើកនៅក្នុងគណនេយ្យរតនាគារជាតិ ។

## ជំពូកទី ៣

## បទបញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដែលបានអនុវត្តក្រៅរតនាគារជាតិ

**មាត្រា ៥** : ត្រូវបានយល់ព្រមតាមការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ក្រៅរតនាគារជាតិ នូវចំណូល ដែលសំរេចបាននិងចំណាយលើសពីការអនុញ្ញាតនៃថវិកាទូទៅមានទឹកប្រាក់ដូចតទៅ ÷

សរុបចំណូល............................ ៨៦.១៨១ លានរៀល

– ចំណូលផ្ទៃក្នុងជាប្រចាំ.......... ........... ២៣.៩០២ លានរៀល

– ចំណូលផ្ទៃក្នុងជាមូលធន....................... ១៩.១១២ លានរៀល

– ចំណូលខាងក្រៅជាមូលធន.................... ៤៣.១៦៧ លានរៀល

សរុបចំណាយ.................................... ៨៦.១៨១ លានរៀល

– ចំណាយជាប្រចាំ................................ ៧២.៦៦៤ លានរៀល

– ចំណាយជាមូលធន:............................ ១៣.៥១៧ លានរៀល

## ជំពូកទី ៤

## បទបញ្ញត្តិស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារ

**មាត្រា ៦** : វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារដែល បានគ្រោងចំណូល ចំណាយនៅក្នុងច្បាប់ស្តីពីការកែតម្រូវឡើងហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

មានចំនួនទឹកប្រាក់ ២៥២.១០០ លានរៀល

ការប៉ាន់ប្រមាណអនុវត្តបានមានចំនួនទឹកប្រាក់ ២៥៦.៧៨៩ លានរៀល

គឺមានចំនួនលើស ៤.៦៨៩ លានរៀល

# ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ៧ :** ចំណូលលំអិតតាមមាតិកាថវិកាត្រូវបានបញ្ជាក់នៅតារាង «ក » ក្នុងភាគទី ២ នៃច្បាប់នេះ ។

ចំណាយអិត តាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទតាមជំពូក ត្រូវបានបញ្ជាក់នៅតារាង «ខ » ក្នុងភាគទី ២ នៃច្បាប់នេះ ។

តារាង «ខ១ » គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៤ និងត្រូវបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបាន ស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និង ចំពោះចំណាយ តាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែលត្រូវបានបញ្ជាក់ជាបន្តបន្ទាប់ នៅតាមតារាង «ក » និង «ខ» ក្នុងភាគទី២ នៃច្បាប់នេះ ។

តារាង «ខ២» គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៤ និងត្រូវបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈ ប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ ឆ្នាំ ១៩៩៤ | ច្បាប់ហិរញ្ញវត្ថុដើម | ច្បាប់ហិញ្ញវត្ថុកែតម្រូវ | ច្បាប់ហិរញ្ញវត្ថុតាមការអនុវត្តបាន |
|---|---|---|---|
| សរុបចំណូល ១ | ៨៨៩.៦០០ | ៨៨៩.៦០០ | ១.០២០.១៣២ |
| សរុបចំណាយ | ៨៨៩.៦០០ | ៨៨៩.៦០០ | ១.០០២.០១៧ |
| ចំណូលលើសចំណាយ | | | ១៨.១១៥ |
| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុតាម | | | |

| | | | |
|---|---|---|---|
| ការអនុវត្តន៍បានដោយរតនាគារជាតិ | ៦២៣.៣០០ | ៦៣៧.៥០០ | ៦៧៧.១៦២ |
| ចំណូលថវិកា | | | |
| - ចំណូលផ្ទៃក្នុងជាប្រចាំ | ៤៦០.០០០ | ៤៩៦.៧០០ | ៥៦៥.២៧០ |
| - ចំណូលផ្ទៃក្នុងជាមូលធន | ០ | ២៣.៨០០ | ១.២៣៧ |
| - ចំណូលខាងក្រៅជាមូលធន | ១៦៣.៣០០ | ១១៧.០០០ | ១១០.៦៥៥ |
| - ចំណាយថវិកា | ៦២៣.៣០០ | ៦៣៧.៥០០ | ៦៥៩.០៤៧ |
| - ចំណាយជាប្រចាំ | ៥៧៧.៦០០ | ៥៨៥.៦០០ | ៥៨៩.៥៨៨ |
| - ចំណាយជាមូលធន | ៤៥.៧០០ | ៥១.៩០០ | ៦៩.៤៥៩ |
| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដែលអនុវត្តក្រៅរតនាគារជាតិចំណូលថវិកា | | | ៨៦.១៨១ |
| - ចំណូលផ្ទៃក្នុងជាប្រចាំ | | | ២៣.៩០២ |
| - ចំណូលផ្ទៃក្នុងជាមូលធន | | | ១៩.១១២ |
| - ចំណូលខាងក្រៅជាមូលធន | | | ៤៣.១៦៧ |
| ចំណាយថវិកា | | | ៨៦.១៨១ |
| - ចំណាយជាប្រចាំ | | | ៧២.៦៦៤ |
| - ចំណាយជាមូលធន | | | ១៣.៥១៧ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅរតនាគារ ធនធានជាមូលធន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស | ២៦៦.៣០០ | ២៥២.១០០ | ២៥៦.៧៨៩ |
| ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស | ២៦៦.៣០០ | ២៥២.១០០ | ២៥៦.៧៨៩ |

**មាត្រា ៨** : បទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជា**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ព្រះហស្តលេខា ហត្ថលេខា**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ
នីតិសម្បទា និង អភិវឌ្ឍន៍ និងជា
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

* * *

# ២ - ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**
**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា